ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# លិខិតជូនពរ

## សូមគោរពជូន
## ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អ៊ឹម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
## នៃព្រះរាជាណាចក្រកម្ពុជា

**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់**

ក្នុងឱកាសចម្រើនជន្មាយុគម្រប់៧៨ឆ្នាំ ឈានចូល៧៩ឆ្នាំ របស់ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត** នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១នេះ យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈទាំងអស់ សូមសម្តែងការចូលរួមអបអរសាទរ និងជូនពរយ៉ាងកក់ក្តៅចំពោះ **ឯកឧត្តម** សូមប្រកបដោយសុខភាពល្អបរិបូរណ៍ កាយពលមាំមួន បញ្ញាញាណវាងវៃ និងជន្មាយុយឺនយូរ។

ឆ្លៀតក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំសូមអនុញ្ញាតសម្តែងនូវទឹកចិត្តយ៉ាងថ្លៃថ្លា និងការដឹងគុណចំពោះសកម្មភាពជាគំរូរបស់ **ឯកឧត្តម** នៅក្នុងបេសកកម្មដឹកនាំក្រុមប្រឹក្សាធម្មនុញ្ញ សម្រេចបាននូវសមិទ្ធផលជាច្រើនជាប្រវត្តិសាស្ត្រដើម្បីបម្រើជាតិ និងប្រជាជន រួមចំណែកយ៉ាងសំខាន់ដល់ការរក្សាបាននូវសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍប្រកបដោយចីរភាព ។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នាសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមប្រោសប្រទានជូន **ឯកឧត្តម និង លោកជំទាវ ព្រមទាំង បុត្រា បុត្រី ចៅប្រុស ចៅស្រី** មានសុខភាពល្អបរិបូរណ៍ និងទទួលបានពុទ្ធពរដ៏មហាប្រសើរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅ និងខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ។

ថ្ងៃ ព្រហស្បតិ៍ ៧កើត ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០២១
**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ**

**រដ្ឋមន្ត្រី**

ព្រុំ-សុខា